**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា

**រដ្ឋសភា**
**ចូល**
លេខ..........
ថ្ងៃទី.......ឆ្នាំ២០១...ម៉ោង....
បញ្ជូនទៅ..........

# សូមគោរពជូន

## សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

**កម្មវត្ថុ :** សេចក្តីស្នើច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**យោង :** -មាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

-ប្រការ២២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាជាតំណាងរាស្ត្រមួយក្រុមដែលជាហត្ថលេខីដូចមានបញ្ជីរាយនាមជូនភ្ជាប់ មានកិត្តិយសសូមផ្ញើជូន **សម្តេចអគ្គមហាពញាចក្រី** នូវសេចក្តីស្នើច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានសេចក្តីថ្លែងហេតុជូនភ្ជាប់មកជាមួយផង ។

យើងខ្ញុំទាំងអស់គ្នា សូមស្នើ **សម្តេចអគ្គមហាពញាចក្រី** មេត្តាពិនិត្យ និងដាក់សេចក្តីស្នើច្បាប់នេះ ជូនរដ្ឋសភាដើម្បីពិភាក្សានិងអនុម័ត ដោយចាត់ទុកជាការប្រញាប់ តាមការគួរ ។

សូម **សម្តេចអគ្គមហាពញាចក្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី២៩ខែឧសភា ឆ្នាំ២០១៣

**តំណាងរាស្ត្រហត្ថលេខី**

បណ្ឌិតរដ្ឋ.ជាម_យៀប

សុខ ឥសាន

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

រដ្ឋសភា
ចូល
លេខ ១៤៧៩
ថ្ងៃទី ... ឆ្នាំ២០១... ម៉ោង ...
បញ្ជូនទៅ ...

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីស្នើច្បាប់
# ស្តីពី
# ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

អនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៣ ជាពិសេសមាត្រា៣១ ដែលចែងអំពីការទទួលស្គាល់ និងការគោរពសិទ្ធិមនុស្សដូចមានចែងក្នុងឧបករណ៍គតិយុត្ត អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ ព្រះរាជាណាចក្រកម្ពុជា បានអនុម័ត ច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើ កិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ដើម្បីជំនួសច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ។ ក្រមព្រហ្មទណ្ឌថ្មី បានបញ្ញត្តបទល្មើសដែលមានលក្ខណៈជាអន្តរជាតិ ក្នុងគន្ថីទី២ ដែលចែងពីបទល្មើសប្រឆាំងនឹងបុគ្គល ហើយដែលចែកចេញជា ៣បទល្មើស : ទី១-បទឧក្រិដ្ឋ ប្រល័យពូជសាសន៍(មាត្រា១៨៣ ដល់ មាត្រា១៨៧) ទី២-បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ (មាត្រា ១៨៨ ដល់ មាត្រា១៩២) និងទី៣-បទឧក្រិដ្ឋសង្គ្រាម (មាត្រា១៩៣ ដល់ មាត្រា១៩៨) ។

សូមរំលឹកថា ក្នុងក្របខណ្ឌនៃការប្រឆាំងនឹងឧក្រិដ្ឋកម្មខាងលើ :

-ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិផ្សេងៗជាអាទិ៍ អនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលអនុម័តដោយ អង្គការសហប្រជាជាតិ នៅឆ្នាំ១៩៤៨ និងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

-នៅក្នុងស្មារតីប្រយុទ្ធប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះដែរ ប្រជាជនកម្ពុជាបាននាំ គ្នាងើបឡើងតស៊ូកំចាត់របបកម្ពុជាប្រជាធិតេយ្យដ៏សាហាវយង់ឃ្នង រហូតដល់ទទួលបានជ័យ ជំនះជាស្ថាពរ នៅថ្ងៃ ៧ មករា ១៩៧៩ ។

-នៅក្នុងក្របខណ្ឌការពារសិទ្ធិមនុស្សនេះដែរ រដ្ឋសភាក៏បានបង្កើតគណៈកម្មការមួយគឺ គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា ដើម្បី រួមចំណែកបង្ការ និងដោះស្រាយរាល់ការរំលោភអំណាចមកលើប្រជាពលរដ្ឋ ។

រដ្ឋសភាតែងយកចិត្តទុកដាក់ជាប្រចាំនូវរាល់ការវិវត្តិនៃបញ្ហាសិទ្ធិមនុស្សក្នុងពិភពលោក នៅក្នុងអង្គប្រជុំទាំងអស់ ទាំងថ្នាក់តំបន់និងអន្តរជាតិ ។ នៅថ្នាក់តំបន់ក្នុងឋានៈជាប្រធាន អាស៊ាន កម្ពុជាបានគាំទ្រ និងជំរុញឱ្យមានការអនុម័តសេចក្តីថ្លែងការស្តីពីសិទ្ធិមនុស្សអាស៊ាន ។ នៅថ្នាក់អន្តរជាតិ យើងបានយកចិត្តទុកដាក់តាមដានរាល់សកម្មភាព និងការសម្រេចថ្មីៗរបស់

អង្គការសហប្រជាជាតិក្នុងវិស័យសិទ្ធិមនុស្ស ជាអាទិ៍ វេទិកាជួបជុំនាថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣ ដែលបានរៀបចំឡើងនៅទីស្នាក់ការអង្គការសហប្រជាជាតិ ដោយបានរំលឹកឡើងវិញនូវរាល់បទឧក្រិដ្ឋប្រល័យពូជសាសន៍ នៅក្នុងពិភពលោកដែលមានមកទល់ពេលនេះ រួមទាំងឧក្រិដ្ឋកម្មនៅកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។

ក្នុងគោលដៅឱ្យប្រជាពលរដ្ឋមានការចងចាំមិនភ្លេចពីប្រវត្តិសាស្ត្រដ៏ជូរចត់ពីអតីតកាល និងរកយុត្តិធម៌ជូនជនរងគ្រោះ ខំប្រឹងប្រែងក្នុងការទប់ស្កាត់កុំឱ្យការកើតមានជាថ្មីនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ស្របតាមឧបករណ៍គតិយុត្តជាតិ និងអន្តរជាតិខាងលើ ព្រមទាំងក្នុងគោលដៅប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការមិនទទួលស្គាល់ឧក្រិដ្ឋកម្មខាងលើនេះ គឺ ជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់វិញ្ញាណក្ខន្ធអ្នកដែលបានបាត់បង់ជីវិតក្នុងសម័យនោះ និងធ្វើឱ្យមានការឈឺចាប់ដល់គ្រួសារជនរងគ្រោះដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ទើបយើងខ្ញុំជាតំណាងរាស្ត្រហត្ថលេខីបានធ្វើសេចក្តីស្នើច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នេះ ។

ស្មារតីគោលក្នុងការធ្វើសេចក្តីស្នើច្បាប់នេះ គឺ រាល់ការមិនទទួលស្គាល់ ឬការសម្រាល ឬការបដិសេធ ឬការជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬការលើកតម្កើងឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មិនត្រូវចាត់ទុកថាជាសេរីភាពក្នុងការបញ្ចេញមតិទេ ។

សេចក្តីស្នើច្បាប់នេះមាន ៥មាត្រា ដែលមានខ្លឹមសារដូចតទៅ :

**មាត្រា១** : គោលដៅគឺផ្តន្ទាទោសរាល់បុគ្គលដែល មិនទទួលស្គាល់ ឬសម្រាល ឬបដិសេធ ឬជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬលើកតម្កើងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

**មាត្រា២** : ការកំណត់ថារាល់អំពើខាងលើ ជាបទល្មើស ព្រហ្មទណ្ឌ ដែលត្រូវ ផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា៣** : ចែងអំពីទោសបន្ថែមដែលមានកំណត់ក្នុងក្រមព្រហ្មទណ្ឌ ។

**មាត្រា៤** : ចែងអំពី នីតិបុគ្គលអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌ ។

**មាត្រា៥** : ចែងអំពីការប្រកាសជាការប្រញាប់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយចាត់ទុកជាការប្រញាប់ តាមការគួរ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៣

*តំណាងតំណាងរាស្ត្រហត្ថលេខី*

**បណ្ឌិតរដ្ឋ ជាម យៀប**

រដ្ឋសភា

សេចក្តីស្នើ


រដ្ឋសភា
ទទួល
គំរោងច្បាប់លើកទី...១.............
ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣


# ច្បាប់

# ស្តីពី

# ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើង ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**មាត្រា១.-**

ច្បាប់នេះ មានគោលដៅផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយណាដែលមិនទទួលស្គាល់ ឬសម្រាល ឬបដិសេធ ឬជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬលើកតម្កើងឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្របតាមបទប្បញ្ញត្តិព្រហ្មទណ្ឌ និងបទដ្ឋាននានាដែលអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

**មាត្រា២.-**

រាល់ការមិនទទួលស្គាល់ ឬការសម្រាល ឬការបដិសេធ ឬការជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬការលើកតម្កើងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ឬដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការដែលមានអានុភាពអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺជាបទមិនទទួលស្គាល់ជាសាធារណៈនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល បទមិនទទួលស្គាល់ជាសាធារណៈនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ តាមមធ្យោបាយណាមួយដូចខាងក្រោម :

១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។




វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា៣.-**

ចំពោះបទល្មើសខាងលើ ទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ដូចខាងក្រោមនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេល ៨ ថ្ងៃ យ៉ាងច្រើន ។

**មាត្រា៤.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២ ខាងលើ ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៣
នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៤
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៣

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**